# លក្ខណៈវ៉ូហ្ពួកនិងតាយ៉ាំមុំហើយនិងការលាងសម្អាត ②

## លក្ខណៈវ៉ូហ្ពួក

នៀវ៉ូហ្ពួកដោយចិត្តរបស់វា បន្ទាប់មកវាពោលថា:ប៊ិសមៀល ឡើហ្ស,ក្រោយមកវាលាងប្រអប់ដៃរបស់វា។



①

រួចវាយកទឹកដោយដៃស្តាំមកខ្ពុរមាត់ "បញ្ចូលទឹកចូលក្នុងមាត់" រួចបញ្ចេញ "គឺយកចេញពីមាត់មកវិញ" រួចស្រូបទឹកតាមរន្ធច្រមុះរបស់វា«គឺស្រូបទឹកតាមរន្ធច្រមុះ» រួចខ្ទាក់មកវិញ «គឺទឹកចេញពីច្រមុះរបស់វាដោយប្រើម្រាមដៃចង្អុលខាងឆ្វេង ហើយនិងមេដៃជំនួយ។



②

រួចវាលាងមុខ "អំពីគល់សក់ធម្មតានៃក្បាលរហូតដល់ពុកចង្កា ខាងក្រោម ហើយ និងទទឹងចន្លោះត្រចៀកទៅត្រចៀកម្ខាងទៀត"។



③

បន្ទាប់មកវាលាងដៃចាប់ពីចុងម្រាមដៃរហូតដល់កែងដៃ ដោយចាប់ផ្តើមពីដៃស្តាំ បន្ទាប់មកខាងឆ្វេង។



④

បន្ទាប់មកវាជូតពេញក្បាលដោយយកដៃជូតពីគល់សក់ខាងមុខក្បាលរហូតទៅខាងក្រោយក្បាលរបស់វា រួចត្រឡប់មកខាងមុខក្បាលវិញ។



⑤

បន្ទាប់មកវាបញ្ចូលម្រាមចង្អុលចូលក្នុងត្រចៀកបន្ទាប់មកជូតដោយមេដៃផ្នែកខាងក្រៅនៃត្រចៀក។



⑥

រួចលាងជើងរួមនឹងភ្នែកជើង។



⑦

- ហ៊ូកុមអំពីការបន្ថែមលើសចំនួនកំណត់នៃច្បាប់ ?

ហាមប្រើលើសពីចំនួនកំណត់ក្នុងការយកវ៉ូហ្ពួក ដូចជាការលាងលើសពីបីដង ឬលាងអ្វីដែលនៅពីលើកែងដៃ ឬអ្វីដែលនៅពីលើភ្នែកជើង ឬក៏ជូតក។ .



⑧

- ឲ្យវាពោលបន្ទាប់ពីយកវ៉ូហ្ពួករួច :

((អាសហ៊ៃឌូអាន់ឡាអ៊ីឡាហៃអ៊ីលលុលឡោះវ៉ះឌើហ៊ូឡើសើរីកើឡះ វ៉ាអាសហ៊ៃឌូអាន់ណាមូហាំម៉ាត់អាប់ឌូហ៊ូវ៉ារ៉ស្ស៊ូលូហ្ស )) ហើយនៅក្នុងស៊ូណាន់តៀរមីស៊ី -(( អល់ឡ៍ហ៊ុំម៉ាច់អាល់នី មីណាត់តាវ៉ាប៊ីន វ៉ាច់អាល់នីមីណាល់មូតាតោះហ៊ីរីន))។

⑨

- អំពីប្រការដែលខូចវ៉ូហ្ពួក។ :

1- អ្វីដែលចេញមកពីពីរផ្លូវ(ខាងមុខ និងខាងក្រោយ) ដូចជាទឹកនោម លាមក ឬផោម។
2- បាត់បង់ស្មារតីដោយដេក ឬសន្លប់។
3- បរិភោគសាច់សត្វអូដ្ឋ។

⑩

## លក្ខណៈតាយ៉ាំមុំ

តាយ៉ាំមុំគឺៈ ជំនួសអំពីការសម្អាតដោយទឹកនៅពេលដែលមានបញ្ហារក្នុងការប្រើប្រាស់ទឹកត្រង់កន្លែងដែលត្រូវសម្អាត ឬខ្វះនៃពួកគេដោយសារតែខ្វះទឹកឬខ្លាចមានគ្រោះថ្នាក់ដោយការប្រើវា ដូច្នេះដីវានឹងជំនួសទឹក។

①

នៀតាយ៉ាំមុំដោយចិត្តរបស់វា ក្រោយមកវាពោលថា:ប៊ិសមិលឡើស ក្រោយមកឲ្យវាវាយតែម្តងគត់ទៅលើដី រួចជូតមុខ និងខ្នងបាតដៃ ។




②

មិនត្រូវបានកំណត់ឱ្យហែកម្រាមដៃនៅពេលដែលវាយទៅលើដីឬក៏មិនចាំបាច់ឈ្លីម្រាមដៃនៅពេលដែលជូតប្រអប់ដៃឡើយ។



③

នៀការលាងសម្អាតដោយចិត្ត ហើយពោលថាប៊ិសមិលឡើសក្នុងចិត្តដោយតិចៗក្រោយមកឲ្យវាលាងសព្វរាងកាយទាំងអស់ទោះបីគ្របដោយរោមតិចឬច្រើនក៏ដោយជាមួយនិងការខ្ពុរមាត់និងស្រូបទឹកចូលច្រមុះ។

①

- ប្រការដែលចាំបាច់ត្រូវលាងសម្អាត :

1- អាល់យើណាហ្គះ: គឺការបញ្ចេញទឹកកាមដោយការរួមភេទ ឬផ្សេងៗទៀតឬដោយការប៉ះគ្នារវាងប្រដាប់ភេទទាំងពីរ។ 2- ធ្លាក់ឈាមរដូវ និងធ្លាក់ឈាមក្រោយពេលសម្រាលកូនរួច។ 3- ស្លាប់ក្រៅពីការស្លាប់សាហីដ។ 4- កាហៀរចូលអ៊ីស្លាម ។

②

និពន្ធដោយ សៀហ្គ ហៃសាំ សារហាន ជាគ្រូបង្រៀននៅម៉ាស្ជិតណាប៊ីហើយក៏អ្នកគ្រប់គ្រងទៅលើម៉ាក់ហិតសុណ្ណះសាលាសុណ្ណះ
mahadusunnah.com

រក្សាសិទ្ធិបោះពុម្ពនិងផ្សព្វផ្សាយនិងបែងចែកផ្តល់លិទ្ធិភាព។ - សម្រាប់បកប្រែក្រដាសតូចៗ sarhaan.com និងស្តេនកូដ។